អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៤

# សេចក្តីប្រកាសព័ត៌មាន

## អង្គជំនុំជម្រះសាលាដំបូងកំណត់វិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០២

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) បានចេញសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីថ្មីមួយដោយកំណត់ទីតាំងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និងការចោទប្រកាន់តាមអង្គហេតុដែលនឹងត្រូវដាក់បញ្ចូលដើម្បីយកមកជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ប្រឆាំងនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន។ ការចោទប្រកាន់ទាំងនេះរួមមាន៖ បទប្រល័យពូជសាសន៍ ការរៀបការដោយបង្ខំ និងបទរំលោភសេពសន្ថវៈ ការប្រព្រឹត្តលើពុទ្ធសាសនិកជន ការបោសសម្អាតផ្ទៃក្នុងបក្ស ការប្រព្រឹត្តិជាក់លាក់លើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ មន្ទីរសន្តិសុខចំនួនបួន ការដ្ឋានការងារចំនួនបី និងសហករណ៍ចំនួនមួយ គឺជាមូលដ្ឋានសម្រាប់ការជំនុំជម្រះនៃសំណុំរឿង ០០២/០២។

មុននឹងសម្រេចបំបែកកិច្ចដំណើរការនីតិវិធីសវនាការ អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃអំពីផលប្រយោជន៍ស្របច្បាប់នានាដែលមានប្រភពមកពីសិទ្ធិមនុស្ស និងគោលការណ៍ស្តីពីប្រសិទ្ធផល។ កត្តាសំខាន់ៗនៃការវិភាគនេះ រួមមាន៖ ផលប៉ះពាល់ដល់សិទ្ធិជនជាប់ចោទដែលអាចកើតមាន ប្រសិទ្ធផល និងភាពដែលអាចគ្រប់គ្រងបាននៃកិច្ចដំណើរការនីតិវិធី គោលបំណងដែលអាចបញ្ចៀសបាននូវភាពមិនស៊ីសង្វាក់គ្នារវាងសវនាការដាច់ដោយឡែកពីគ្នា និងបន្ទុកទៅលើសាក្សីដែលអាចកើតមាន។ កត្តាមួយទៀតដែលអាចគួរឲ្យពិចារណាផងដែរនោះគឺថា ការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីគឺជាការចាំបាច់ ដើម្បីធានាយ៉ាងហោចណាស់ឲ្យមានការជំនុំជម្រះផ្នែកមួយចំនួននៃការចោទប្រកាន់ ក្នុងអំឡុងពេលដែលជនជាប់ចោទនៅរស់រានមានជីវិត ។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការបំបែកកិច្ចដំណើរការនីតិវិធីសវនាការនៃសំណុំរឿង ០០២ បន្ថែម គឺដើម្បីជាប្រយោជន៍យុត្តិធម៌ និងមិនប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទឡើយ។

ក្រោយពីបានសម្រេចបំបែកកិច្ចដំណើរការនីតិវិធីសវនាការរួចមក អង្គជំនុំជម្រះសាលាដំបូងបានសម្រេចកំណត់វិសាលភាពនៃអង្គហេតុសម្រាប់យកមកធ្វើសវនាការ។ ដើម្បីកំណត់វិសាលភាពនេះបាន អង្គជំនុំជម្រះសាលាដំបូងបានពិចារណាទៅលើលក្ខខណ្ឌនានាដែលតម្រូវឲ្យមានការជំនុំជម្រះដោយយុត្តិធម៌ និងឆាប់រហ័ស ព្រមទាំង

“ជាតំណាងសមស្រប” នៃដីកាដំណោះស្រាយទាំងមូល។ ក្រោយពីបានពិចារណាទៅលើសេចក្តីសន្និដ្ឋានសុំរបស់ភាគីនានា អង្គជំនុំជម្រះសាលាដំបូងបាន សម្រេចយកទីតាំងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និងការចោទប្រកាន់តាមអង្គហេតុខាងក្រោមនេះ មកធ្វើជាមូលដ្ឋានសម្រាប់ការជំនុំជម្រះនៃសំណុំរឿង ០០២/០២៖

- បទប្រល័យពូជសាសន៍ចំពោះជនជាតិចាម និងវៀតណាម (ដោយមិនរាប់បញ្ចូលបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិដែលបានប្រព្រឹត្តដោយកងទ័ពបដិវត្តកម្ពុជាក្នុងទឹកដីវៀតណាម)
- ការរៀបការដោយបង្ខំ និងបទរំលោភសេពសន្ថវៈ (ទូទាំងប្រទេស)
- ការបោសសម្អាតផ្ទៃក្នុង
- មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង មន្ទីរសន្តិសុខភ្នំក្រោល
- ការដ្ឋានទំនប់ ១ មករា ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ការដ្ឋានទំនប់ត្រពាំងថ្ម
- សហករណ៍ត្រាំកក់
- ការប្រព្រឹត្តិចំពោះពុទ្ធសាសនិកជន (កម្រិតត្រឹមតែសហករណ៍ត្រាំកក់)
- ការប្រព្រឹត្តិជាក់លាក់លើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (ដែលអនុវត្តកម្រិតត្រឹមតែសហករណ៍ត្រាំកក់ ការដ្ឋានទំនប់ ១ មករា មន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់)។

អង្គជំនុំជម្រះសាលាដំបូង នឹងបង្គាប់ឲ្យភាគីទាំងអស់ដាក់បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងបញ្ជីឯកសារភស្តុតាង ដែលខ្លួនមានបំណងស្នើសុំដាក់បញ្ចូលសម្រាប់ជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ។ អង្គជំនុំជម្រះសាលាដំបូងនឹងកំណត់កាលបរិច្ឆេទសវនាការបឋម សម្រាប់សំណុំរឿង ០០២/០២ បន្ទាប់ពីបានទទួលបញ្ជីទាំងអស់នេះរួចរាល់ហើយ។

សំណុំរឿង ០០២/០២ គឺជាសំណុំរឿងទីពីរដែលបំបែកចេញមកពីដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២។ កាលពីថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២ ឲ្យទៅជាសំណុំរឿងពីរ ឬច្រើន។ សំណុំរឿង ០០២/០១ ដែលត្រូវបានបំបែកទីមួយបានផ្តោតការយកចិត្តដាក់ជាចម្បងទៅលើបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលពាក់ព័ន្ធនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងការជម្លៀសប្រជាជនពីតំបន់ដទៃទៀត (ដំណាក់កាលទី ១ និងដំណាក់កាលទី ២) និងការចោទប្រកាន់ពីការសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរនៅទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ បន្ទាប់ពីខ្មែរក្រហមដណ្តើមបានអំណាចក្នុងឆ្នាំ ១៩៧៥ ភ្លាម។ សេចក្តីសន្និដ្ឋានបញ្ចប់ ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០១ នេះ បានបញ្ចប់កាលពីថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ ហើយបច្ចុប្បន្ននេះ អង្គជំនុំជម្រះសាលាដំបូងកំពុងតែបំពេញការងាររបស់ខ្លួនដើម្បីអាចចេញសាលក្រមនៃរឿងក្តីនេះក្នុងត្រីមាសទីពីរឆ្នាំ ២០១៤ ខាងមុខនេះ។

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Porsenchey, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទចល័តៈ +៨៥៥ (០) ១២ ៤៨៨ ០២៣
សារអេឡិកត្រូនិកៈ olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទចល័តៈ +៨៥៥ (០) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិកៈ neth.pheaktra@eccc.gov.kh